ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០០៧ សហវ

# សារាចរណែនាំ
## ស្តីពី
## ការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ដំណាក់កាលទី១ ជំហានទី២

អនុវត្តតាមកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងយុទ្ធសាស្ត្រកៀរគរចំណូលរបស់រាជរដ្ឋាភិបាល ដើម្បីគ្រប់គ្រងចំណូលមិនមែនសារពើពន្ធប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានបង្កើតប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (Non-Tax Revenue Management Information System-NRMIS) ដែលបានដាក់ឱ្យអនុវត្តរួចរាល់នៅដំណាក់កាលទី១ ជំហានទី១ ចំនួន ១៤ ក្រសួង ស្ថាប័ន តាមរយៈសារាចរណែនាំលេខ០០៣ សហវ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៨ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

នៅក្នុងដំណាក់កាលទី១ ជំហានទី២ នេះ ប្រព័ន្ធ NRMIS នឹងដាក់ឱ្យអនុវត្តសម្រាប់ក្រសួង ស្ថាប័ន ចំនួន០៩ រួមមាន៖ ក្រសួងព្រះបរមរាជវាំង, ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា, ក្រសួងការពារជាតិ, ក្រសួងព័ត៌មាន, ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងបរិស្ថាន, ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា, ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងក្រសួងយុត្តិធម៌។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងបន្តរៀបចំលេខកូដចំណូលមិនមែនសារពើពន្ធជាមួយមន្ទីរជំនាញរាជធានី ខេត្ត, រដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គភាពប្រមូលចំណូលមិនមែនសារពើពន្ធផ្សេងៗទៀត នៅក្នុងជំហានបន្ទាប់។

ក្រសួង ស្ថាប័នទាំង ០៩ ខាងលើ ត្រូវប្រើប្រាស់លេខកូដចំណូលមិនមែនសារពើពន្ធដែលបានកំណត់ដោយលម្អិតតាមចំណូលពីសេវាសាធារណៈ, ចំណូលពីទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធផ្សេងៗទៀត។ គ្រប់ចំណូលមិនមែនសារពើពន្ធទាំងអស់ដែលអាចបង់ចូលថវិការដ្ឋបាន លុះត្រាណាតែមានលេខកូដចំណូល ដែលអនុម័តដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានរតនាគារជាតិ ឬ អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ) តាមការស្នើសុំរបស់ក្រសួង ស្ថាប័នសាមី។ បញ្ជីលេខកូដចំណូលមិនមែនសារពើពន្ធ នៃក្រសួង ស្ថាប័ននីមួយៗជាឧបសម្ព័ន្ធនៃសារាចរណែនាំនេះ។

ដើម្បីមានមូលដ្ឋានក្នុងការប្រើប្រាស់លេខកូដចំណូលមិនមែនសារពើពន្ធពីចំណូលសេវាសាធារណៈ, ចំណូលពីទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធផ្សេងៗទៀត សម្រាប់ក្រសួង ស្ថាប័ន ចំនួន ០៩ នៅរដ្ឋបាលថ្នាក់ជាតិ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសម្រេចដាក់ចេញនូវសេចក្តីណែនាំអំពីនីតិវិធីនៃការប្រមូលនិងកត់ត្រាចំណូលទៅក្នុងប្រព័ន្ធ NRMIS និងបង់ចំណូលទៅធនាគារជាតិនៃកម្ពុជា ធនាគារដៃគូ ឬ/និងគ្រឹះស្ថានហិរញ្ញវត្ថុដៃគូ ដូចខាងក្រោម៖


ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរសព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ: ៨៥៥-២៣-៤២៧ ៧៩៨
Phone: 855-23-724 664 Fax : 855-23-427 798

១. ការកត់ត្រាចំណូលទៅក្នុងប្រព័ន្ធ NRMIS ÷ ក្រសួង ស្ថាប័ន ក្រោយពីទទួលបានចំណូលពីសេវាសាធារណៈ, ចំណូលពីទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធផ្សេងៗទៀត ត្រូវកត់ត្រាចំណូលទៅក្នុងប្រព័ន្ធ NRMIS។

២. ពេលបង់ចំណូលទៅធនាគារជាតិនៃកម្ពុជា, ធនាគារដៃគូ ឬ/និងគ្រឹះស្ថានហិរញ្ញវត្ថុដៃគូ÷

- ចំពោះចំណូលពីទ្រព្យសម្បត្តិរដ្ឋ ក្រសួង ស្ថាប័ន ត្រូវបោះពុម្ពវិក្កយបត្រចេញពីប្រព័ន្ធ NRMIS ជូនអតិថិជន ដើម្បីបង់ប្រាក់នៅធនាគារជាតិនៃកម្ពុជា, ធនាគារដៃគូ ឬ/និងគ្រឹះស្ថានហិរញ្ញវត្ថុដៃគូ
- ចំពោះចំណូលពីសេវាសាធារណៈ ក្រសួង ស្ថាប័ន ត្រូវបោះពុម្ពវិក្កយបត្រចេញពីប្រព័ន្ធ NRMIS ចំនួន០២ច្បាប់ ដោយ០១ច្បាប់ រក្សាទុកជូនធនាគារជាតិនៃកម្ពុជា,ធនាគារដៃគូ ឬ/និងគ្រឹះស្ថានហិរញ្ញវត្ថុដៃគូ និង ០១ច្បាប់ទៀត រក្សាទុកដោយរដ្ឋទេយ្យករចំណូល ឬ គណនេយ្យករចំណូលរបស់ក្រសួង ស្ថាប័ន ដើម្បីភ្ជាប់ជាមួយសាច់ប្រាក់ដែលត្រូវបង់ ឬ បង្វែរ (គណនីចរន្តរបស់ក្រសួង ស្ថាប័ន) ចូលគណនីទោលរតនាគារ (TSA) នៅធនាគារជាតិនៃកម្ពុជា
- ចំពោះចំណូលមិនមែនសារពើពន្ធផ្សេងៗទៀត ក្រសួង ស្ថាប័ន អាចអនុវត្តតាមនីតិវិធីនៃការបង់ចំណូលចំពោះចំណូលពីសេវាសាធារណៈ ឬ ចំណូលពីទ្រព្យសម្បត្តិរដ្ឋតាមយថាប្រភេទនៃចំណូលជាក់ស្តែង
- ក្រោយពីបានបង់ប្រាក់ចូល TSA ក្រសួង ស្ថាប័ន ត្រូវកត់ត្រាលេខយោងលើប័ណ្ណបង់ប្រាក់ (Bank Slip) ឬ ប្រកាសឥណពន្ធ (Debit Advice) ឬ ប័ណ្ណផ្ទេរប្រាក់/ឥណទាន (Remittance Slip) ចូលក្នុងប្រព័ន្ធ NRMIS ដើម្បីបញ្ចប់ប្រតិបត្តិការនៃការបោះពុម្ពវិក្កយបត្រ (ក្នុងករណីជាប្រាក់ដុល្លារត្រូវបញ្ចូលអត្រាប្តូរប្រាក់ទៅតាមអត្រាប្តូរប្រាក់ប្រចាំថ្ងៃ ដែលចេញដោយធនាគារជាតិនៃកម្ពុជា)។

៣. ការបង្វែរចំណូលទៅថវិកាជាតិ÷

- ក្រសួង ស្ថាប័ន ជ្រើសរើសយកប្រតិបត្តិការដែលបានបង់ចូល TSA ដើម្បីបោះពុម្ពសលាកបត្របង់ចំណូលថវិកាជាតិចេញពីប្រព័ន្ធ NRMIS
- រដ្ឋទេយ្យករចំណូល ឬ គណនេយ្យករចំណូលត្រូវពិនិត្យនិងចុះហត្ថលេខាលើសលាកបត្របង់ចំណូលថវិកាជាតិ រួចបញ្ជូនមកអគ្គនាយកដ្ឋានរតនាគារជាតិជាមុន តាមរយៈប្រព័ន្ធទំនាក់ទំនងសង្គម Telegram របស់ក្រសួង ស្ថាប័ននីមួយៗដែលបានបង្កើតរួចជាស្រេចនាពេលកន្លងមក។ រីឯ ឯកសារច្បាប់ដើមត្រូវដាក់ជូនថ្នាក់ដឹកនាំរបស់ក្រសួង ស្ថាប័នសាមីចុះហត្ថលេខា រួចបញ្ជូនមកអគ្គនាយកដ្ឋានរតនាគារជាតិតាមក្រោយ។

៤. ការទូទាត់ប្រាក់រង្វាន់÷ ដើម្បីរៀបចំការទូទាត់ប្រាក់រង្វាន់ដែលក្រសួង ស្ថាប័ន បានបុរេប្រទានពីថវិកាជាតិកន្លងមក ក្រសួង ស្ថាប័ន ត្រូវប្រើប្រាស់ប្រព័ន្ធ NRMIS ដោយត្រូវជ្រើសរើសយកសលាកបត្របង់ចំណូលថវិកាជាតិ តាមរយៈសាច់ប្រាក់ដែលបានបង់ចូល TSA។ បន្ទាប់មកត្រូវបោះពុម្ពលិខិតស្នើសុំផ្សេងៗ និងរបាយការណ៍ស្ថានភាពស្តីពីការអនុវត្តចំណូល,តារាងសម្រង់សលាកបត្របង់ចំណូលថវិកាជាតិ និងប័ណ្ណបង់ប្រាក់, តារាងគណនាប្រាក់រង្វាន់ និងរបាយការណ៍ស្តីពីការបែងចែកប្រាក់រង្វាន់ដែលបានបើកផ្តល់កន្លងមក និងផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីអនុវត្តនីតិវិធីបន្ត។

បន្ទាប់ពីទទួលបានសារាចរណែនាំនេះ ក្រសួង ស្ថាប័ន ត្រូវរៀបចំសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរបន្ថែមទៀតទៅអ្នកជាប់កាតព្វកិច្ចបង់ចំណូល និងធនាគារដៃគូ ឬ/និងគ្រឹះស្ថានហិរញ្ញវត្ថុដៃគូរបស់ក្រសួង ស្ថាប័នសាមីឱ្យប្រើប្រាស់លេខកូដសម្រាប់ការបង់ចំណូលជាកំហិត។

ក្រសួង ស្ថាប័ន ចំនួន ០៩ ខាងលើ ត្រូវអនុវត្តសារាចរណែនាំនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៨ តទៅ។

ថ្ងៃពុធ ១០កើត ខែភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ២០១៨

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**<u>ចម្លងជូន៖</u>**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
"ដើម្បីជូនជ្រាប"
-ក្រសួង ស្ថាប័ន ចំនួន០៩
-អគ្គនាយកដ្ឋានរតនាគារជាតិ
-អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ
"ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ